**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តត្បូងឃ្មុំ**
សំណុំរឿងរដ្ឋប្បវេណីលេខ ៨២
ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២២
**សាលក្រមរដ្ឋប្បវេណី**
**លេខៈ ៣៤ (ក)**
ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តត្បូងឃ្មុំ**

ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធាននៃសាលាដំបូងខេត្តត្បូងឃ្មុំ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តត្បូងឃ្មុំ

- **ដើមចោទៈ** ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៧២ ជនជាតិខ្មែរ មុខរបរ ជាងសំណង់ មានទីលំនៅបច្ចុប្បន្ន នៅផ្ទះ [redacted] ។

ដោយមានលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

- **ចុងចម្លើយៈ** ឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ មុខរបរ នៅផ្ទះ មានទីលំនៅបច្ចុប្បន្ន [redacted] ។

## អង្គហេតុ និង ចំណុចទាស់ទាង

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

សុំឱ្យតុលាការសម្រេចចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម៖

១-បែងចែកទ្រព្យដែលមានជាមួយចុងចម្លើយជាពីរចំណែកស្មើរគ្នា លើអចលនវត្ថុដែលមានអត្តសញ្ញាណដូចខាងក្រោម៖

១.១. ដីចំការមួយកន្លែង ទំហំ ៦០៧៦ ម² (ប្រាំមួយពាន់ចិតសិបប្រាំមួយម៉ែត្រការ៉េ) ដែលមានក្បាលដីលេខ ៤០៨ តាងដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៣០៨០៥-០៤០៨ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៨ (ដោយបច្ចុប្បន្នមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីលេខ ២៥០៣០៨០៥-០៤០៨ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២២) ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។



Scanned with CamScanner

១.២. ដី និងផ្ទះ ដែលមានក្បាលដីលេខ P២៩៣ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងដីរបស់ឈ្មោះ [redacted] ប៊ាង ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted] វ៉ាន់ឌី ខាងលិចទល់នឹងផ្លូវលំ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦ ដែលមានការដឹងឮពីប្រធានសន្តិសុខបុរីតេជោសែន ។

១.៣. ដី និងផ្ទះ ដែលមានក្បាលដីលេខ P៣១៨ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងក្បាលដីលេខ P៣០៥ ខាងកើតទល់នឹងក្បាលដីលេខ P ៣១៧ ខាងលិចទល់នឹងក្បាលដីលេខ P៣១៩ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៣ របស់ភូមិសាឡង់២ ។

១.៤. ដីលំនៅឋានដែលមានក្បាលដីលេខ ២៥២ ទំហំ ៧០ ម (ចិតសិបម៉ែត្រ) គុណនឹង ៨ ម (ប្រាំបីម៉ែត្រ) ស្មើនឹងទំហំសរុប ៥៦០ ម² (ប្រាំរយហុកសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] ហុង ខាងត្បូងទល់នឹងផ្លូវជាតិលេខ៧ ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted] សក់ស្ត ខាងលិចទល់នឹងដីរបស់ឈ្មោះ [redacted] ហុង មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ដីផ្តាច់លេខ ១០៥១៩/១៩ ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៩ របស់មេឃុំមេមត់ ។

១.៥. ដីលំនៅឋាន ទំហំ ១៣ ម (ដប់បីម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) ស្មើនឹងទំហំសរុបប្រហែល ៣៩០ ម² (បីរយកៅសិបម៉ែតការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ ឃាត ខាងត្បូងទល់នឹងផ្លូវលំ ខាងលិចទល់នឹងដីរបស់ឈ្មោះ រ៉េត មានទីតាំងស្ថិតនៅនៅភូមិសំរោងជើង (បុរីតេជោ) ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧ របស់មេភូមិសំរោងជើង ។

១.៦. ដីចំការ ទំហំ ៤៦ ម (សែសិបប្រាំមួយម៉ែត្រ) គុណនឹង ២០០ ម (ពីររយម៉ែត្រ) ស្មើនឹងទំហំសរុបប្រហែល ៩.២០០ ម² (ប្រាំបួនពាន់ពីររយម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីឈ្មោះ [redacted] ម៉ាលីទីន ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងអូរ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ ដោយមានលិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ ។

១.៧. ដីចំនាការ ទំហំ ២០,៥ ម (ម្ភៃក្បៀសប្រាំម៉ែត្រ) គុណនឹង ៣០០ ម (បីរយម៉ែត្រ) ស្មើរនឹងទំហំសរុបប្រហែល ៦.១៥០ ម² (ប្រាំមួយពាន់មួយរយហាសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] គេង ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងផ្លូវរទេះ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ ដោយមានលិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ ។

២-បង្គាប់ឱ្យមន្ត្រីអាជ្ញាធរសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ ធ្វើនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិ និងកម្មសិទ្ធិលើចំណែក



Scanned with CamScanner

ទ្រព្យដែលបែងចែកនីមួយៗមកឱ្យដើមចោទ ។

៣-សុំអនុវត្តសាលក្រមជាបណ្តោះអាសន្នទៅលើចំណុចទី១ និងចំណុចទី២ ។

៤-ប្រាក់ប្រដាប់ក្តីតុលាការជាបន្ទុករបស់ចុងចម្លើយ ។

**ខ. អង្គហេតុនៃរឿងក្តី និងចំណុចវិវាទ**

**ខ.១. អង្គហេតុនៃរឿងក្តី**

កាលពីអំឡុងឆ្នាំ២០១៧ ភាគីដើមចោទឈ្មោះ [redacted] ផាកាយផន ភេទប្រុស កើតឆ្នាំ១៩៧២ បានរួមរស់នៅជាមួយចុងចម្លើយឈ្មោះ [redacted] ស្រីនី ភេទស្រី កើតឆ្នាំ១៩៨១ ដូចជាប្តីប្រពន្ធ នៅក្នុងភូមិសំរោងជើង ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ នៅអំឡុងពេលរួមរស់នៅជាមួយគ្នានោះ ភាគីទាំងពីរមានកូនចំនួន ០១នាក់ និងបានរួមគ្នាបង្កើតជាទ្រព្យសម្បត្តិបានមួយចំនួន។ ក្រោយមក ភាគីដើមចោទ និងចុងចម្លើយ បានរស់នៅមិនចុះសម្រុងនឹងគ្នា ក៏បានបែកបាក់គ្នាទៅវិញ ចំណែកទ្រព្យសម្បត្តិដែលបានរួមគ្នាបង្កើតឡើងនោះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចុងចម្លើយឈ្មោះ [redacted] ស្រីនី ទាំងស្រុង ហើយដើមចោទឈ្មោះ [redacted] ផាកាយផន ចេញទៅធ្វើការនៅក្រៅប្រទេស (ចេញចូលក្នុងប្រទេសជាញឹកញាប់)។ រហូតមកដល់ពេលនេះ ស្រាប់តែដើមចោទទទួលដំណឹងថា ចុងចម្លើយបានចាត់ចែងទ្រព្យមួយចំនួនដោយគ្មានការអនុញ្ញាតពីដើមចោទ ទើបធ្វើដើមចោទដាក់ពាក្យបណ្តឹងទាមទារបែងចែកទ្រព្យជាមួយចុងចម្លើយមកសាលាដំបូងខេត្តត្បូងឃ្មុំតែម្តង ។

**ខ.២. ចំណុចដែលគ្មានវិវាទ**

ភាគីចុងចម្លើយឈ្មោះ [redacted] ស្រីនី តុលាការបានធ្វើការបញ្ជូនដីកាកោះទៅចុងចម្លើយលើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ យ៉ាងត្រឹមត្រូវ ដោយចុងចម្លើយឈ្មោះ [redacted] ស្រីនី បានទទួលដីកាកោះរបស់តុលាការហើយ តែចុងចម្លើយបានលះបង់សិទ្ធិមិនចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ។ យោងតាមត្រា ២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានទទួលស្គាល់ថា ចុងចម្លើយទទួលស្គាល់តាមការទាមទាររបស់ដើមចោទទាំងស្រុង ដោយគ្មានការវិវាទ ។

**ខ.៣. ចំណុចដែលមានវិវាទ**

១.ការប្តឹងទាមទារបែងចែកទ្រព្យរបស់ដើមចោទនេះ ត្រឹមត្រូវដែរ ឬទេ?

២.តើការទាមប្តឹងទារឱ្យតុលាការបង្គាប់ឱ្យមន្ត្រីអាជ្ញាធរសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ ធ្វើនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិ និងកម្មសិទ្ធិលើចំណែកទ្រព្យដែលបែងចែកនីមួយៗមកឱ្យដើមចោទនោះ ត្រឹមត្រូវដែរ ឬទេ?

៣.តើតុលាការអាចប្រកាសអនុវត្តជាបណ្តោះអាសន្នលើការប្តឹងទាមទារត្រង់ចំណុចទី១ និងចំណុចទី២ របស់ដើមចោទដែរ ឬទេ?

**គ. សេចក្តីអះអាងថ្លែងការណ៍របស់គូភាគី**

-សេចក្តីអះអាងថ្លែងការណ៍របស់លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យភាគីដើមចោទលើ

ចំណុចវិវាទ៖ កាលពីអំឡុងឆ្នាំ២០១៧ កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] ផាកាយឥន ភេទប្រុស បានរួមរស់នៅជាមួយចុងចម្លើយឈ្មោះ [redacted] ស្រីនី ភេទស្រី ដូចជាប្តីប្រពន្ធ នៅក្នុងភូមិសំរោងជើង ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ នៅអំឡុងពេលរួមរស់នៅជាមួយគ្នានោះ ភាគីទាំងពីរមានកូនចំនួន ០១នាក់ (តែភាគីចុងចម្លើយឈ្មោះ [redacted] ស្រីនី បានលាក់ប្រវត្តិកូនមិនឱ្យដើមចោទដឹងនោះទេ) ហើយពេលរួមរស់នៅជាមួយគ្នានោះដែរ ចុងចម្លើយឈ្មោះ [redacted] ស្រីនី បានបបួលកូនក្តីខ្ញុំបាទឈ្មោះ [redacted] ផាកាយឥន ឱ្យទិញដីជាច្រើនកន្លែង ដោយលុយថ្លៃទិញដីទាំងនោះ គឺជាលុយរបស់កូនក្តីខ្ញុំបាទទាំងស្រុង ដោយចុងចម្លើយឈ្មោះ [redacted] ស្រីនី គឺគ្រាន់តែចេញកម្លាំងមើលថែរក្សាទ្រព្យទាំងអស់នោះតែប៉ុណ្ណោះ ព្រោះកូនក្តីខ្ញុំបាទត្រូវចេញទៅធ្វើការនៅក្រៅប្រទេសជាច្រើនពេល។ ក្រោយមក នៅអំឡុងឆ្នាំ២០២០ ចុងចម្លើយឈ្មោះ [redacted] ស្រីនី មានគំនិតទុច្ចរិត ដោយបង្កជាបញ្ហាជម្លោះផ្សេងៗ ដោយគ្មានមូលហេតុ ធ្វើឱ្យដើមចោទមិនអាចរួមរស់នៅជាមួយគ្នាទៀតបាន ហើយក៏បានរស់នៅបែកគ្នា។ បន្ទាប់មក កូនក្តីខ្ញុំបាទឈ្មោះ [redacted] ផាកាយឥន ក៏បានដឹងដំណឹងថា ចុងចម្លើយឈ្មោះ [redacted] ស្រីនី បានលួចធ្វើឯកសារថ្មីជាមួយអ្នកលក់ និងបានលួចលក់ដីមួយចំនួន ដែលបានយកលុយពីកូនក្តីខ្ញុំបាទទិញនោះស្ទើតែទាំងអស់ ធ្វើឱ្យកូនក្តីខ្ញុំបាទអស់មនោសញ្ចេតនា ដោយការរំលោភបំពានសិទ្ធិ និងផលប្រយោជន៍របស់ក្តីខ្ញុំបាទ ទើបធ្វើកូនក្តីខ្ញុំបាទដាក់ពាក្យបណ្តឹងទាមទារបែងចែកទ្រព្យជាមួយចុងចម្លើយមកតុលាការនៃសាលាដំបូងខេត្តត្បូងឃ្មុំតែម្តង។ ដូចនេះ ខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ផាកាយឥន សូមធ្វើការទាមទារឱ្យតុលាការចេញសេចក្តីសម្រេចដូចខាងក្រោមនេះ ៖

១-បែងចែកទ្រព្យដែលមានជាមួយចុងចម្លើយជាពីរចំណែកស្មើគ្នា លើអចលនវត្ថុដែលមានអត្តសញ្ញាណដូចខាងក្រោម៖

១.១. ដីចំការមួយកន្លែងទំហំ ៦០៧៦ ម$^{២}$ (ប្រាំមួយពាន់ចិតសិបប្រាំមួយម៉ែត្រការ៉េ) ដែលមានក្បាលដីលេខ ៤០៨ តាងដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៣០៨០៥-០៤០៨ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៨ (ដោយប្តូរប្បន្នមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីលេខ ២៥០៣០៨០៥-០៤០៨ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២២) ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។

១.២. ដី និងផ្ទះ ដែលមានក្បាលដីលេខ P២៩៣ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងដីរបស់ឈ្មោះ [redacted] ហ៊ាង ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted] វ៉ាន់នី ខាងលិចទល់នឹងផ្លូវលំ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦ ដែលមានការដឹងឮពីប្រធានសន្តិសុខបុរីតេជោសែន ។

១.៣. ដី និងផ្ទះ ដែលមានក្បាលដីលេខ P៣១៨ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងក្បាលដីលេខ P៣០៥ ខាងកើតទល់នឹងក្បាលដីលេខ P ៣១៧ ខាងលិចទល់នឹងក្បាលដីលេខ P៣១៩ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ



Scanned with CamScanner

តាងដោយកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៣ របស់ភូមិសាឡុង២ ។

១.៤. ដីលំនៅឋានដែលមានក្បាលដីលេខ ២៥២ ទំហំ ៧០ ម (ចិតសិបម៉ែត្រ) គុណនឹង ៨ ម (ប្រាំបីម៉ែត្រ) ស្មើនឹងទំហំសរុប ៥៦០ ម² (ប្រាំរយហុកសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] ហុង ខាងត្បូងទល់នឹងផ្លូវជាតិលេខ៧ ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted] សភ័ស្ត ខាងលិចទល់នឹងដីរបស់ឈ្មោះ [redacted] ហុង មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ដីផ្តាច់លេខ ១០៥១៩/១៩ ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៩ របស់មេឃុំមេមត់ ។

១.៥. ដីលំនៅឋាន ទំហំ ១៣ ម (ដប់បីម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) ស្មើនឹងទំហំសរុប ប្រហែល ៣៩០ ម² (បីរយកៅសិបម៉ែតការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ ឃាត ខាងត្បូងទល់នឹងផ្លូវលំ ខាងលិចទល់នឹងដីរបស់ឈ្មោះ រ៉េត មានទីតាំងស្ថិតនៅនៅភូមិសំរោងជើង (បុរីតេជោ) ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧ របស់មេភូមិសំរោងជើង ។

១.៦. ដីចំការ ទំហំ ៤៦ ម (សែសិបប្រាំមួយម៉ែត្រ) គុណនឹង ២០០ ម (ពីររយម៉ែត្រ) ស្មើនឹងទំហំសរុប ប្រហែល ៩.២០០ ម² (ប្រាំបួនពាន់ពីររយម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីឈ្មោះ [redacted] ម៉ាលីទីន ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងអូរ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ ដោយមានលិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ ។

១.៧. ដីចំការ ទំហំ ២០,៥ ម (ម្ភៃក្បៀសប្រាំម៉ែត្រ) គុណនឹង ៣០០ ម (បីរយម៉ែត្រ) ស្មើរនឹងទំហំសរុប ប្រហែល ៦.១៥០ ម² (ប្រាំមួយពាន់មួយរយហាសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] គេង ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងផ្លូវរទេះ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ ដោយមានលិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ ។

២-បង្គាប់ឱ្យមន្ត្រីអាជ្ញាធរសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ ធ្វើនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិ និងកម្មសិទ្ធិលើចំណែកទ្រព្យដែលបែងចែកនីមួយៗមកឱ្យដើមចោទ ។

៣-សុំអនុវត្តសាលក្រមបណ្តោះអាសន្នទៅលើចំណុចទី១ និងចំណុចទី២ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

-ភាគីចុងចម្លើយឈ្មោះ [redacted] ស្រីនី៖ កាលពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការបានធ្វើការបញ្ជូនដីកាកោះទៅភាគីចុងចម្លើយចំនួន ០២លើក លើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងត្រឹមត្រូវ ដោយភាគីចុងចម្លើយឈ្មោះ [redacted] ស្រីនី បានទទួលដីកាកោះរបស់តុលាការហើយ តែភាគីចុងចម្លើយបានលះបង់សិទ្ធិមិនចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ហើយនៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីចុងចម្លើយក៏បានទទួលដីកា



Scanned with CamScanner

កោះរបស់តុលាការផងដែរ ក៏ប៉ុន្តែភាគីចុងចម្លើយនៅតែបន្តលះបង់សិទ្ធិមិនចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដដែល ។

## សំអាងហេតុ

**ឆ្លងតាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿងរួចរាល់ តុលាការឃើញថា៖**

### ១. ស្តីពីសមត្ថកិច្ចតុលាការលើបណ្តឹង៖

ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២២ របស់លោកមេធាវី [redacted] និងលោកមេធាវី [redacted] ដែលជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ជាកាយឥន ធ្វើឡើងដោយត្រឹមត្រូវតាមទម្រង់នៃមាត្រា ៧៥ មាត្រា ៥២ និងមាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ពាក្យបណ្តឹងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ជាកាយឥន នេះ គឺប្តឹងទាមទារឱ្យតុលាការសម្រេចបែងចែកទ្រព្យសម្បត្តិ ហើយការប្តឹងសុំបែងចែកទ្រព្យសម្បត្តិនេះ គឺស្ថិតនៅក្នុងប្រភេទ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ដែលបណ្តឹងនេះតម្រូវឱ្យតុលាការរដ្ឋប្បវេណីជាអ្នកមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណី ស្របតាមមាត្រា ១៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។ យោងតាមមាត្រា ៨ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថា "សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានរបស់ចុងចម្លើយ" ហើយចុងចម្លើយឈ្មោះ [redacted] ស្រីនី មានលំនៅឋានបច្ចុប្បន្ន [redacted] ដែលកំណត់ថា តុលាការនៃសាលាដំបូងខេត្តត្បូងឃ្មុំ មានសមត្ថកិច្ចក្នុងដំណើរកិច្ចនីតិវិធីលើពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ជាកាយឥន នេះ។ ដូចនេះ តុលាការយល់ឃើញថា ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២២ របស់លោកមេធាវី [redacted] និងលោកមេធាវី [redacted] ដែលជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ជាកាយឥន ធ្វើឡើងដោយត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

### ២. ស្តីពីចំណុចវិវាទលើការទាមទារបែងចែកទ្រព្យសម្បត្តិ៖

- ឆ្លងកាត់តាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការបានចេញដីកាកោះចុងចម្លើយឈ្មោះ [redacted] ស្រីនី និងបានធ្វើការបញ្ជូនដីកាកោះទៅភាគីចុងចម្លើយយ៉ាងត្រឹមត្រូវទៅតាមច្បាប់ ដោយភាគីចុងចម្លើយឈ្មោះ [redacted] ស្រីនី បានទទួលដីកាកោះរបស់តុលាការហើយ តែភាគីចុងចម្លើយបានលះបង់សិទ្ធិមិនចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ។ ការលះបង់សិទ្ធិមិនចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់របស់ចុងចម្លើយនេះ តុលាការចាត់ទុកថា ភាគីចុងចម្លើយឈ្មោះ [redacted] ស្រីនី បានសារភាពតាមសេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ និងទទួលស្គាល់ថា ការប្តឹងទាមទាររបស់ភាគីដើមចោទ គឺពិតជាត្រឹមត្រូវ ស្របតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។
- លោកមេធាវី [redacted] ដែលជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ជាកាយឥន បានធ្វើសេចក្តីថ្លែងការណ៍ថា៖ កាលពីអំឡុងឆ្នាំ២០១៧ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ជាកាយឥន ភេទប្រុស បានរួមរស់នៅជាមួយ

ចុងចម្លើយឈ្មោះ [redacted] ស្រីនី ភេទស្រី ដូចជាប្តីប្រពន្ធ ស្ថិតនៅក្នុងភូមិសំរោងជើង ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ នៅអំឡុងពេលរួមរស់នៅជាមួយគ្នានោះ ភាគីទាំងពីរមានកូនចំនួន ០១នាក់ (តែភាគីចុងចម្លើយឈ្មោះ [redacted] ស្រីនី បានលាក់ប្រវត្តិកូនមិនឱ្យដើមចោទដឹងនោះទេ) ហើយពេលរួមរស់នៅជាមួយគ្នានោះដែរ ចុងចម្លើយឈ្មោះ [redacted] ស្រីនី បានបបួលកូនក្តីខ្លួនឈ្មោះ [redacted] ផាកាយឥន ឱ្យទិញដីជាច្រើនកន្លែង ដោយលុយថ្លៃទិញដីទាំងនោះ គឺជាលុយរបស់កូនក្តីខ្លួនទាំងស្រុង ដោយចុងចម្លើយឈ្មោះ [redacted] ស្រីនី គឺគ្រាន់តែចេញកម្លាំងមើលថែរក្សាទ្រព្យទាំងអស់នោះតែប៉ុណ្ណោះ។ ស្របគ្នាទៅនឹងសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទនេះ គឺលោកមេធាវីក៏បានដាក់ភស្តុតាងឱ្យតុលាការពិនិត្យរួមមាន៖ ១. វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៣០៨០៥-០៩០៨ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៨ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ, ២. វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីលេខ ២៥០៣០៨០៥-០៩០៨ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២២ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ ៣. កិច្ចសន្យាលក់ផ្តាច់លេខ ១៥៣/១៩ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៩ ចេញដោយមេឃុំមេមត់, ៤. កិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦ ដែលមានការដឹងឮពីប្រធានសន្តិសុខបុរីតេជោសែន, ៥. កិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៣ របស់មេភូមិសាឡង់២, ៦. កិច្ចសន្យាលក់ដីផ្តាច់លេខ ១០៥១៩/ ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៩ របស់មេឃុំមេមត់, ៧. កិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧ របស់មេភូមិសំរោងជើង, ៨. លិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ, ៩. លិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ។ គ្រប់លិខិតបញ្ជាក់លើអចលនវត្ថុខាងលើ គឺសុទ្ធតែមានឈ្មោះភាគីដើមចោទឈ្មោះ [redacted] ផាកាយឥន និងចុងចម្លើយឈ្មោះ [redacted] ស្រីនី បានរួមគ្នាទិញក្នុងនាមជាប្តី និងប្រពន្ធ ដែលនាំឱ្យតុលាការជឿជាក់ថា ទ្រព្យសម្បត្តិដែលជាអចលនវត្ថុរួមមាន៖ ១. ដីចំការមួយកន្លែងទំហំ ៦០៧៦ ម² (ប្រាំមួយពាន់ចិតសិបប្រាំមួយម៉ែត្រការ៉េ) ដែលមានក្បាលដីលេខ ៩០៨ មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ២. ដី និងផ្ទះ ដែលមានក្បាលដីលេខ P២៩៣ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងដីរបស់ឈ្មោះ [redacted] ប៉ិកាង ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted] វ៉ាន់ឌី ខាងលិចទល់នឹងផ្លូវលំ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ៣. ដី និងផ្ទះ ដែលមានក្បាលដីលេខ P៣១៨ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងក្បាលដីលេខ P៣០៥ ខាងកើតទល់នឹងក្បាលដីលេខ P៣១៧ ខាងលិចទល់នឹងក្បាលដីលេខ P៣១៩ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ៤. ដីលំនៅឋានដែលមានក្បាលដីលេខ ២៥២ ទំហំ ៧០ ម (ចិតសិបម៉ែត្រ) គុណនឹង ៨ ម (ប្រាំបីម៉ែត្រ) ស្មើនឹងទំហំសរុប ៥៦០ ម² (ប្រាំរយហុកសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] ហុង ខាងត្បូងទល់នឹងផ្លូវជាតិលេខ៧ ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted] សភ័ស្ត ខាងលិចទល់នឹងដីរបស់ឈ្មោះ [redacted] ហុង មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្ត



Scanned with CamScanner

ត្បូងឃ្មុំ, ៥. ដីលំនៅឋាន ទំហំ ១៣ ម (ដប់បីម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) ស្មើនឹងទំហំសរុបប្រហែល ៣៩០ ម² (បីរយកៅសិបម៉ែតការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ ឃាត ខាងត្បូងទល់នឹងផ្លូវលំ ខាងលិចទល់នឹងដីរបស់ឈ្មោះ រ៉េត មានទីតាំងស្ថិតនៅនៅភូមិសំរោងជើង (បុរីតេជោ) ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ៦. ដីចំការ ទំហំ ៤៦ ម (សែសិបប្រាំមួយម៉ែត្រ) គុណនឹង ២០០ ម (ពីររយម៉ែត្រ) ស្មើនឹងទំហំសរុបប្រហែល ៩.២០០ ម² (ប្រាំបួនពាន់ពីររយម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីឈ្មោះ [redacted] ម៉ាលីទីន ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងអូរ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ, និង ៧. ដីចំនាការ ទំហំ ២០,៥ ម (ម្ភៃក្បៀសប្រាំម៉ែត្រ) គុណនឹង ៣០០ ម (បីរយម៉ែត្រ) ស្មើរនឹងទំហំសរុបប្រហែល ៦.១៥០ ម² (ប្រាំមួយពាន់មួយរយហាសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] តេង ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងផ្លូវរទេះ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ គឺជាទ្រព្យសម្បត្តិដែលភាគីដើមចោទ និងចុងចម្លើយបានបង្កើតឡើងរួមគ្នា ហើយមានចំណែកកម្មសិទ្ធិរួមគ្នាប្រាកដមែន ។

-ក្រោយពីតុលាការពិនិត្យលើចំណងទំនាក់ទំនងរវាងគូភាគីដើមចោទ និងចុងចម្លើយ គឺគ្រាន់តែបានរួមរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធ ក៏ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដើម្បីបង្កើតចំណងអាពាហ៍ពិពាហ៍ស្របតាមបញ្ញត្តិនៃមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងមាត្រា ៣០ និងមាត្រា ៣១ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលកម្ពុជានោះឡើយ។ គូភាគីទាំងពីរមិនជាប់ចំណងអាពាហ៍ពិពាហ៍តាមកំណត់ច្បាប់នោះទេ ហើយទ្រព្យសម្បត្តិដែលគូភាគីដើមចោទ និងចុងចម្លើយបានរួមគ្នាបង្កើតឡើងមកនេះ គឺមិនមែនជាទ្រព្យសម្បត្តិរួមស្របតាមមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីនោះឡើយ គឺជាទ្រព្យសម្បត្តិដែលស្ថិតក្នុង **កម្មសិទ្ធិអវិភាគ** របស់គូភាគីដើមចោទ និងចុងចម្លើយ ស្របតាមមាត្រា ២០២ នៃក្រមរដ្ឋប្បវេណី។ ចំណែកទ្រព្យសម្បត្តិនៃកម្មសិទ្ធិអវិភាគរបស់ភាគីដើមចោទ និងចុងចម្លើយ គឺត្រូវបានសន្មតថា ស្មើគ្នា ស្របតាមមាត្រា ២០៣ នៃក្រមរដ្ឋប្បវេណី។ ដោយមានភស្តុតាងដាក់ឱ្យតុលាការពិនិត្យ និងបានបញ្ជាក់យ៉ាងច្បាស់ទៅលើកម្មសិទ្ធិអវិភាគរបស់គូភាគីលើទ្រព្យសម្បត្តិដែលជាអចលនវត្ថុទាំងអស់ ដែលភាគីដើមចោទបានដាក់ប្តឹងសុំឱ្យតុលាការសម្រេចបែងចែកទៅជាពីរចំណែកស្មើគ្នានោះ គប្បីតុលាការពិចារណាសម្រេចទៅតាមការប្តឹងសុំរបស់ភាគីដើមចោទនេះ ស្របទៅតាមមាត្រា ២១២ នៃក្រមរដ្ឋប្បវេណី ។

**៣. ស្តីពីចំណុចវិវាទលើការទាមទារឱ្យតុលាការសម្រេចបង្គាប់ឱ្យមន្ត្រីអាជ្ញាធរសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ ធ្វើនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិ និងកម្មសិទ្ធិលើចំណែកដែលបានបែងចែកនីមួយៗមកឱ្យដើមចោទ៖**

- ភាគីដើមចោទបានប្តឹងសុំឱ្យតុលាការសម្រេចបង្គាប់ឱ្យមន្ត្រីអាជ្ញាធរសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ ធ្វើនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិ និងកម្មសិទ្ធិលើចំណែកទ្រព្យដែលបែងចែកនីមួយៗមកឱ្យដើមចោទ។ ការប្តឹងសុំនេះអាចអនុវត្តទៅ



Scanned with CamScanner

បានលុះត្រាតែសេចក្តីសម្រេចរបស់តុលាការបានចូលជាស្ថាពរ ដោយពុំមានភាគីណាមួយប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍ ស្របតាមមាត្រា ២០៤ និងមាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ គូភាគីអាចដាក់ពាក្យសុំសាលក្រមស្ថាពរ សុំរូបមន្តអនុវត្ត និងដាក់ពាក្យអនុវត្តដោយបង្ខំ ស្របតាមបទបញ្ញត្តិនានានៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីឱ្យតុលាការអនុវត្តចេញសេចក្តីសម្រេចបង្គាប់ឱ្យមន្ត្រីអាជ្ញាធរសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ ធ្វើនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិ និងកម្មសិទ្ធិលើចំណែកទ្រព្យសម្បត្តិដែលបានបែងចែកនីមួយៗមកឱ្យដើមចោទបាន ។

**៤. ស្តីពីវិវាទលើការប្តឹងសុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្នលើការប្តឹងទាមទារត្រង់ចំណុចទី១ និងទី២ ខាងលើ របស់ដើមចោទ៖**

- ចំពោះការប្តឹងទាមទារឱ្យតុលាការសម្រេចប្រកាសអនុវត្តសាលក្រមជាបបណ្តោះអាសន្ន ទៅលើការប្តឹងទាមទារត្រង់ចំណុចទី១ និងចំណុចទី២ របស់ដើមចោទនេះ គឺតុលាការយល់ឃើញថា ពុំទាន់អាចប្រកាសអនុវត្តបាននៅឡើយទេ ព្រោះការប្តឹងទាមទារឱ្យបែងចែកទ្រព្យសម្បត្តិដែលជាអចលនវត្ថុ គឺវាមិនងាយស្រួលបែងចែកដូចគ្នាទៅនឹងការបែងចែកទ្រព្យសម្បត្តិដែលជាចលនវត្ថុនោះទេ ដោយត្រូវរង់ចាំសាលក្រមចូលជាស្ថាពរជាមុនសិន ហើយត្រូវបានអនុវត្តដោយតុលាការអនុវត្ត និងមានការស្រាវជ្រាវអចលនវត្ថុដោយមន្ត្រីអាជ្ញាសាលា និងធ្វើការបែងចែកទៅតាមទំហំជាក់ស្តែងលើទ្រព្យសម្បត្តិដែលជាអចលនវត្ថុនីមួយៗនោះដោយតុលាការអនុវត្ត។ ក្រោយពីអនុវត្តបែងចែករួចរាល់ ទើបអាចឱ្យមន្ត្រីអាជ្ញាធរមានសត្ថកិច្ចចុះបញ្ជីលើចំណែកទ្រព្យសម្បត្តិរបស់គូភាគីរៀងៗខ្លួនបាន ។

**៥. ស្តីពីប្រាក់ប្រដាប់ក្តីក្រៅពីពន្ធរបស់តុលាការ៖**

- ប្រាក់ប្រដាប់ក្តីតុលាការ គឺជាបន្ទុករបស់ភាគីអ្នកចាញ់ក្តី អនុលោមតាមមាត្រា ៦៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១. ទទួលយកពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២២ របស់លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] **ផាភាយផន** ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២. បែងចែកទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគរបស់គូភាគីដើមចោទឈ្មោះ [redacted] **ផាភាយផន** និងចុងចម្លើយឈ្មោះ [redacted] **ស្រីនី** ជាពីរចំណែកស្មើរគ្នា លើអចលនវត្ថុដែលមានអត្តសញ្ញាណដូចខាងក្រោម៖

២.១. ដីចំការមួយកន្លែង ទំហំ ៦០៧៦ ម$^{២}$ (ប្រាំមួយពាន់ចិតសិបប្រាំមួយម៉ែត្រការ៉េ) ដែលមានក្បាលដីលេខ ៤០៨ តាងដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៣០៨០៥-០៤០៨ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៨ (ដោយឬប្បន្នមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីលេខ ២៥០៣០៨០៥-០៤០៨ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២២) ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។



Scanned with CamScanner

២.២. ដី និងផ្ទះ ដែលមានក្បាលដីលេខ P២៩៣ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងដីរបស់ឈ្មោះ [redacted] ប៊ាង ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted]ភ័ន្ធី ខាងលិចទល់នឹងផ្លូវលំ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦ ដែលមានការដឹងឮពីប្រធានសន្តិសុខបុរីតេជោសែន ។

២.៣. ដី និងផ្ទះ ដែលមានក្បាលដីលេខ P៣១៨ ទំហំ ២០ ម (ម្ភៃម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងក្បាលដីលេខ P៣០៥ ខាងកើតទល់នឹងក្បាល់ដីលេខ P៣១៧ ខាងលិចទល់នឹងក្បាលដីលេខ P៣១៩ មានទីតាំងស្ថិតនៅភូមិបុរីតេជោ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៣ របស់ភូមិសាឡង់២ ។

២.៤. ដីលំនៅឋានដែលមានក្បាលដីលេខ ២៥២ ទំហំ ៧០ ម (ចិតសិបម៉ែត្រ) គុណនឹង ៨ ម (ប្រាំបីម៉ែត្រ) ស្មើនឹងទំហំសរុប ៥៦០ ម² (ប្រាំរយហុកសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] ហុង ខាងត្បូងទល់នឹងផ្លូវជាតិលេខ៧ ខាងកើតទល់នឹងដីរបស់ឈ្មោះ [redacted]សភ័ស្ត ខាងលិចទល់នឹងដីរបស់ឈ្មោះ [redacted]ហុង មានទីតាំងស្ថិតនៅភូមិសង្គមានជ័យថ្មី ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាងដោយកិច្ចសន្យាលក់ដីផ្តាច់លេខ ១០៥១៩/១៩ ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៩ របស់មេឃុំមេមត់ ។

២.៥. ដីលំនៅឋាន ទំហំ ១៣ ម (ដប់បីម៉ែត្រ) គុណនឹង ៣០ ម (សាមសិបម៉ែត្រ) ស្មើនឹងទំហំសរុបប្រហែល ៣៩០ ម² (បីរយកៅសិបម៉ែតការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ ឃាត ខាងត្បូងទល់នឹងផ្លូវលំ ខាងលិចទល់នឹងដីរបស់ឈ្មោះ ង៉ែត មានទីតាំងស្ថិតនៅនៅភូមិសំរោងជើង (បុរីតេជោ) ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧ របស់មេភូមិសំរោងជើង ។

២.៦. ដីចំការ ទំហំ ៤៦ ម (សែសិបប្រាំមួយម៉ែត្រ) គុណនឹង ២០០ ម (ពីររយម៉ែត្រ) ស្មើនឹងទំហំសរុបប្រហែល ៩.២០០ ម² (ប្រាំបួនពាន់ពីររយម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីឈ្មោះ [redacted] ម៉ាលីទីន ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងអូរ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ ដោយមានលិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ ។

២.៧. ដីចំនាការ ទំហំ ២០,៥ ម (ម្ភៃក្បៀសប្រាំម៉ែត្រ) គុណនឹង ៣០០ ម (បីរយម៉ែត្រ) ស្មើរនឹងទំហំសរុបប្រហែល ៦.១៥០ ម² (ប្រាំមួយពាន់មួយរយហាសិបម៉ែត្រការ៉េ) មានព្រំប្រទល់ ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] គេង ខាងត្បូងទល់នឹងដីរបស់ឈ្មោះ ម៉ាន ខាងកើតទល់នឹងផ្លូវរទេះ ខាងលិចទល់នឹងផ្លូវរទេះ មានទីតាំងស្ថិតនៅភូមិប៉ោដើមស្វាយ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ ដោយមានលិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៨ របស់មេភូមិប៉ោដើមស្វាយ ។



Scanned with CamScanner

៣. អនុញ្ញាតឱ្យមន្ត្រីអាជ្ញាធរសុរិយោដី មន្ត្រីអាជ្ញាធរភូមិបាល និងមន្ត្រីអាជ្ញាធរពាក់ព័ន្ធ ធ្វើនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិ និងកម្មសិទ្ធិលើចំណែកទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគរបស់គូភាគីដើមចោទ និងចុងចម្លើយ ដែលបានសម្រេចបែងចែកតាមចំណែកនីមួយៗខាងលើឱ្យទៅគូភាគីដើមចោទ និងចុងចម្លើយ (ត្រង់ចំណុចទី២ នៃសេចក្ដីសម្រេច) ក្រោយពេលសាលក្រមរដ្ឋប្បវេណីនេះបានចូលជាស្ថាពរ និងមានពាក្យសុំអនុវត្តត្រឹមត្រូវតាមកំណត់ច្បាប់ ។

៤. ច្រានចោលការប្ដឹងទាមទារឱ្យតុលាការសម្រេចប្រកាសអនុវត្តសាលក្រមជាបបណ្ដោះអាសន្ន ទៅលើការប្ដឹងទាមទារត្រង់ចំណុចទី១ និងចំណុចទី២ របស់ភាគីដើមចោទ ខាងលើនេះ ។

៥. ប្រាក់ប្រដាប់ក្ដីតុលាការជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមរដ្ឋប្បវេណីនេះ ត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៣ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ តែកំបាំងមុខចុងចម្លើយ ។

ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា៖** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៦កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦

**បានឃើញ**

ខេត្តត្បូងឃ្មុំ, ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

[redacted]

ខេត្តត្បូងឃ្មុំ, ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner